កាលបរិច្ឆេទៈ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៩

# មេរៀនដំណាំស្ពៃចង្កឹះ

## បច្ចេកទេសនៃការដាំស្ពៃចង្កឹះ

### ១.ការរៀបចំដី

- ភ្ជួរដីហាលដីរយៈពេលពី៧ទៅ១៥ថ្ងៃ
- ត្រូវភ្ជួររំប្រែដីឱ្យបាន២ទៅ៣ដងក្នុងជម្រៅពី២ទៅ៣តឹក។

### ២.ការរៀបចំថ្នាលឬរង

☺ ធ្វើរងទទឹងយកប្រវែង១ម៉ែត្រ បណ្តោយតាមលទ្ធភាពដី

☺ ត្រូវលើកកំពស់រងពី១៥ទៅ២០ស.ម នៅក្នុងរដូវប្រាំង រីឯរដូវវស្សាត្រូវលើករងកំពស់ពី២០ស.ម ទៅ៣០ស.ម។

☺ ត្រូវធ្វើដីឱ្យម៉ដ្តល្អនិងហាលវារយៈពេលបីថ្ងៃ មុនយកគ្រាប់ពូជទៅសាបលើថ្នាល។

រៀបចំដោយលោក យុក សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

## ៧.ការដាំដុះ

- ប្រើជីធម្មជាតិពី១ទៅ២បង្គីសម្រាប់ដាក់ទ្រាប់បាតរង ហើយច្របល់ជីនោះជាមួយដីរងឱ្យបានសព្វល្អ។
- យកគ្រាប់ស្ពៃចង្កឹះទៅហាលថ្ងៃរយៈពេល៣០នាទី ហើយយកវាទៅត្រាំទឹករយៈពេល៣ម៉ោង បន្ទាប់មកផ្អាប់វានៅក្នុងធុងទឹកកករយៈពេល១យប់។
- យកដីខ្សាច់៤ភាគច្របល់ជាមួយគ្រាប់ពូជស្ពៃ បន្ទាប់មកយកវាទៅសាបលើថ្នាល។
- នៅពេលកូនស្ពៃអាយុបានពី១០ទៅ១៥ថ្ងៃ យើងអាចយកវាទៅស្ទូងបាន(២០ស.ម គុណនឹង ២០ស.ម)។

### + ការដាំគ្រាប់ដោយផ្ទាល់:

- ត្រូវសាបគ្រាប់ពូជរង្វាល់ល្មមបន្ទាប់ពីត្រាំទឹករួច
- រោយកំទេចចំបើងពីលើរង
- ស្រោចទឹកវាឱ្យបានជោគបន្ទាប់ពីរោយកំទេចចំបើង
- មុនសាបគ្រាប់ពូជត្រូវស្រោចទឹករងឱ្យបានជោគជាមុនសិន។

## ៩.ការថែទាំ

- ត្រូវជ្រោយដី
- ដកស្មៅ
- ស្រោចទឹកស្ពៃចង្កឹះឱ្យបានជោគល្អនិង
- ត្រូវមើលសត្វល្អិតជាប្រចាំ។

## ៩.ការប្រមូលផល

✓ នៅពេលស្ពៃចង្កឹះអាយុបានពី២០ទៅ២៥ថ្ងៃ យើងអាចប្រមូលផលបានហើយ។

✓ ស្ពៃចង្កឹះត្រូវបានគេប្រមូលផលនៅក្នុងពេលព្រឹកនៅម៉ោង៧ទៅម៉ោង១០ព្រឹក និងនៅពេលរសៀលនៅម៉ោង៣ទៅម៉ោង៦។

✓ ត្រូវបញ្ឈប់ការស្រោចទឹករយៈពេល២ថ្ងៃមុនពេលប្រមូលផល

✓ ការប្រមូលផលស្ពៃចង្កឹះគឺយោងទៅលើតម្រូវការទីផ្សារផងដែរ៕

**សូមអរគុណ**

រៀបចំដោយលោក យុក សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

កាលបរិច្ឆេទៈ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៩

# មេរៀនដំណាំត្រឡាច

## បច្ចេកទេសនៃការដាំស្ពៃចង្កឹះ

### ១.ការជ្រើសរើសពូជ

ពូជត្រឡាចមានច្រើនប្រភេទដូចជា៖

- ត្រឡាចពូជស្រាល
- ត្រឡាចពូជកណ្តាលនិង
- ត្រឡាចពូជធ្ងន់។

### ២.ការរៀបចំដី

- កាប់ឬភ្ជួរដីហាលរយៈពេលពី៧ទៅ១៥ថ្ងៃ
- បន្ទាប់មកត្រូវភ្ជួររាស់ប្រែដីឱ្យបាន២ទៅ៣ដងទៀតក្នុងជម្រៅពី២តឹកទៅ៣តឹក។

## ៣.ការរៀបចំរង

❖ រងទទឹងអាចត្រូវបានគេភ្ជួរលើករង រងទទឹងស្មើ២ទៅ៣ម៉ែត្រឬ៧តឹក។ ប្រសិនបើប្រវែង៧តឹក ត្រូវទុកចន្លោះរងស្មើ២ទៅ៣ម៉ែត្រ។

❖ កំពស់រង= ១៥ទៅ ២០ស.ម និង២០ទៅ៣០ស.ម ដោយអាស្រ័យទៅលើស្ថានភាពដី។

❖ ត្រូវកាប់ជារណ្តៅនៅចំកណ្តាលរងបណ្តោយ រណ្តៅមានទំហំ២តឹក៤ជ្រុងដោយទុកគម្លាតពីគ្នា១២០ទៅ១៥០ស.ម ឬពី៨០ស.មទៅ១០០ស.ម។

+ **ករណីសម្រាប់ដីមានជីជាតិនៅក្នុងរដូវប្រាំង៖**

គេ(កសិករ)គ្រាន់តែភ្ជួរដីឱ្យបានច្រើនដងសារចុះសារឡើង បន្ទាប់មកកាប់រណ្តៅ រួចហើយដាក់ដាំត្រឡាចតែម្តង។

## ៤.ការដាំដុះ

- ត្រូវលាងសម្អាតគ្រាប់ពូជ ហើយបន្ទាប់មកទៀតយកវាទៅហាលថ្ងៃរយៈពេលពី២ទៅ៣ម៉ោង។
- យកគ្រាប់ពូជដាក់ត្រាំទឹករយៈពេល១យប់និងផ្អាប់វារយៈពេល១យប់ដែរ បន្ទាប់មកយកវាទៅដាំ។ ត្រូវយកជីកំប៉ុស្តិ៍ដាក់ក្នុងរណ្តៅហើយ

ច្របល់ជាមួយដីនៅក្នុងរណ្តៅឱ្យបានសព្វល្អ ក្រោយមកទៀតកាយលុបដីបំពេញរណ្តៅ។

- ដាក់គ្រាប់ដាំ៣ទៅ៤គ្រាប់សម្រាប់មួយរណ្តៅ
- ស្រោចទឹកឱ្យបានឆាប់បន្ទាប់ពីដាំរួច
- ត្រឡាចអាចដាក់ឱ្យវារនៅលើដីឬធ្វើទ្រើងឱ្យវាវារក៏បាន។

**+ ចំណាំ៖**

ប្រសិនបើលោកអ្នកចង់ឱ្យត្រឡាចមានផ្លែច្រើន លោកអ្នកត្រូវតែកាត់ទងរបស់វាម្តងនៅពេលវាលូតលាស់បាន៧ថ្នាំង។ នៅពេលខ្នែងត្រឡាចលូតបាន៧ថ្នាំង ត្រូវកាត់ត្រួយវាចេញម្តងទៀត។ នៅពេលខ្នែងដែលត្រូវគេកាត់ចេញនោះលូតបាន៧ថ្នាំងទៀតត្រូវកាត់ត្រួយរបស់វាចេញម្តងទៀត។ លោកអ្នកធ្វើដូចនេះ វានឹងធ្វើឱ្យត្រឡាចរបស់លោកអ្នកមានផ្លែច្រើនជាក់ជាមិនខានឡើយ។

## ៥.ការថែទាំ

- ត្រូវពិនិត្យមើលកូនត្រឡាចនៅពេលវាលូតលាស់បានអាយុពី៧ទៅ១៥ថ្ងៃ អាចដកកូនត្រឡាចចេញខ្លះ(បើមានច្រើនដើម)។
- បោចស្មៅ
- ជ្រុំជើងត្រឡាច

- ដាក់ជីបំប៉ននិង
- ស្រោចទឹកត្រឡាចឱ្យបានជោគល្អ។

## ៥.ការប្រមូលផល

✓ ត្រឡាចអាចប្រមូលផលបានចាប់ពី៤០ថ្ងៃទៅ៥០ថ្ងៃសម្រាប់ត្រឡាចពូជស្រាល។

✓ ការប្រមូលផលគឺអាស្រ័យទៅលើតម្រូវការទីផ្សារផងដែរ៕

**សូមអរគុណ**

រៀបចំដោយលោក យុក សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)